**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៦៥ ប្រក កសក

# ប្រកាស
# ស្តីពី
# ការដាក់ឲ្យប្រើប្រាស់និមិត្តសញ្ញាគុណភាព ផល ផលិតផលជលផល

---

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលទំនិញ និងសេវា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្មនិងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យ នៃម្ហូបអាហារសម្រាប់មនុស្ស

- បានឃើញប្រកាសអន្តរក្រសួងលេខ៨៦៨ ឧរថ.ប្រក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០ ស្តីពីការអនុវត្តន៍ និងការរៀបចំសម្របសម្រួលស្ថាប័នកិច្ច នៃប្រព័ន្ធគ្រប់គ្រងសុវត្ថិភាពម្ហូបអាហារ ចាប់ពីកសិដ្ឋានផលិត ដល់តុបរិភោគ
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល

## សម្រេច

### ប្រការ ១.-

ប្រកាសនេះមានគោលបំណងដាក់ឲ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពសម្រាប់បញ្ជាក់គុណភាព សុវត្ថិភាព ផល ផលិតផលជលផលនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ ២.-

ប្រកាសនេះមានគោលដៅៈ

- ជម្រុញការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងគុណភាព សុវត្ថិភាពលើផល ផលិតផលជលផល
- បង្កើនតម្លៃបន្ថែមចំពោះផល ផលិតផលជលផល
- ការពារសុខភាពសាធារណៈនិងបង្កើនទំនុកចិត្តអ្នកប្រើប្រាស់
- លើកទឹកចិត្តដល់វារីវប្បករ អ្នកផ្គត់ផ្គង់ អ្នកប្រមូលទិញនិងអ្នកកែច្នៃ ព្រមទាំងបង្កើនភាពប្រកួតប្រជែងទីផ្សារ និងជំរុញការនាំចេញ។

### ប្រការ ៣.-

អនុញ្ញាតឲ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល ដែលមានវិសាលភាពអនុវត្តលើផល ផលិតផលជលផលដែលបានពីធម្មជាតិនិងវារីវប្បកម្ម សម្រាប់ទីតាំងទិញ លក់ កន្លែងកែច្នៃ ក្រុមហ៊ុននាំចេញ សមាគមកែច្នៃផល ផលិតផលជលផលនិងកន្លែងវារីវប្បកម្ម។

ទម្រង់និងខ្លឹមសារលម្អិតនៃនិមិត្តសញ្ញាគុណភាពផល ផលិតផលជលផលមានភ្ជាប់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

### ប្រការ ៤.-

រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល ត្រូវបំពេញលក្ខខណ្ឌតម្រូវបច្ចេកទេសនិងស្នើសុំមករដ្ឋបាលជលផល។

លក្ខខណ្ឌតម្រូវបច្ចេកទេសនិងបែបបទនៃការផ្តល់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល ត្រូវកំណត់ដោយរដ្ឋបាលជលផល។

ការផ្តល់និងការគ្រប់គ្រងការប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល ជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល។

**ប្រការ ៥ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលមានកាតព្វកិច្ចបង់ថ្លៃសេវាសាធារណៈលើការស្នើសុំប្រើប្រាស់និមិត្តសញ្ញាគុណភាព ផល ផលិតផលជលផលដែលកំណត់ដោយប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

**ប្រការ ៦ .-**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលប្រើប្រាស់និមិត្តសញ្ញានេះដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ ៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៨ .-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងយុត្តិធម៌
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-គ្រប់សាលាខេត្ត-រាជធានី
-ដូចប្រការ ៨
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

## ឧបសម្ព័ន្ធ

ភ្ជាប់ប្រកាសលេខ..៥៦៥.ចុះថ្ងៃទី ២៦.. ខែកញ្ញា ឆ្នាំ២០១៦ ស្ដីពី "ការដាក់ឲ្យប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល" ។

ផជ XXX-YY/ZZ

## រចនាបទនិងខ្លឹមសារ

១. រចនាបទ

និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល មានលក្ខណៈដូចខាងក្រោម៖

- និមិត្តសញ្ញាគុណភាពផល ផលិតផលជលផលមានទំហំតូចឬធំ ត្រូវសមាមាត្រទៅនឹងគំរូ
- រង្វង់ខាងក្រៅ រាងជាកងចក្រពណ៌មាសព័ទ្ធជុំវិញ
- រង្វង់ខាងក្នុង រាងជាខ្សែរង្វង់មូលពណ៌បៃតងមានចំនួនពីរខ្សែដែលនៅចន្លោះខ្សែទាំងពីរ នៅផ្នែកខាងលើរំលេចដោយអក្សរ **ផល ផលិតផលមានគុណភាព** នៅផ្នែកកណ្តាលមានសញ្ញា ✓ ពណ៌បៃតងសងខាងចំនួនពីរ និងនៅផ្នែកខាងក្រោមរំលេចដោយអក្សរអង់គ្លេស QUALITY CERTIFIED ។
- រង្វង់មូលខាងក្នុងមានផ្ទៃពណ៌ស ផ្នែកខាងលើមានរូបត្រីពណ៌ខៀវលាយស និងនៅផ្នែកខាងក្រោមមានរូបទឹករលកចំនួន៧ ពណ៌ខៀវចាស់ លាយពណ៌ខៀវខ្ចីដែលរំលេចដោយជាយពណ៌ស។
- លេខសំគាល់ **ផខ** XXX-YY/ZZ
    - **ផខ**: ផល ផលិតផលជលផល
    - XXX: លេខអ្នកទទួលសិទ្ធិប្រើប្រាស់និមិត្តសញ្ញាគុណភាពផល ផលិតផលជលផល
    - YY : លេខរៀងផល ផលិតផលជលផល
    - ZZ : លេខកូដសំគាល់ឆ្នាំអនុញ្ញាតឲ្យប្រើនិមិត្តសញ្ញាគុណភាពផល ផលិតផលជលផល

២. ខ្លឹមសារ

- រង្វង់កងចក្រខាងក្រៅ ពណ៌មាស តំណាងឲ្យផល ផលិតផលមានគុណភាពល្អ
- ខ្សែរង្វង់មូលខាងក្នុងពណ៌បៃតង តំណាងឲ្យការថែរក្សាបរិស្ថាននិងប្រព័ន្ធអេកូឡូស៊ី
- សញ្ញា✓ ពណ៌បៃតងតំណាងឲ្យផល ផលិតផលជលផលត្រូវបានត្រួតពិនិត្យគុណភាពសុវត្ថិភាព
- រូបទឹករលកចំនួន៧ ពណ៌ខៀវចាស់ លាយពណ៌ខៀវខ្ចីដែលរំលេចដោយជាយពណ៌ស តំណាងឲ្យធនធានជលផល
- រូបត្រីពណ៌ខៀវលាយស តំណាងឲ្យផល ផលិតផលជលផល ។

## គំរូនិមិត្តសញ្ញាគុណភាពផល ផលិតផលជលផល

